**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤០៧៥ សហវ.ហសសភអ

ថ្ងៃ ៥ រោច ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០២៣

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ:** គោលការណ៍ណែនាំស្តីពីការស្នើសុំ និងទូទាត់ថវិកាបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ ជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជ្រាបថា កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្កេតឃើញថា ដោយមានតម្រូវការក្នុងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបនឹងតម្រូវការនិងសំណូមពរបន្ទាន់របស់ប្រជាពលរដ្ឋ រដ្ឋបាលរាជធានី ខេត្តមួយចំនួនបានស្នើសុំថវិកាបុរេប្រទានសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ ជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋាន មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលការអនុវត្តបែបនេះ បង្កឱ្យមានផលអវិជ្ជមានដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអាចបង្កឱ្យមានបញ្ហាបំណុលសាធារណៈសម្រាប់រដ្ឋនៅក្នុងរយៈពេលមធ្យម និងវែងទៅមុខជាយថាហេតុ។ លើសពីនេះ រដ្ឋបាលរាជធានី ខេត្តនីមួយៗ ក៏បាត់បង់នូវលទ្ធភាពក្នុងការអនុវត្តគម្រោងវិនិយោគសាធារណៈនានា ក្នុងរយៈពេលមធ្យមខាងមុខផងដែរ។

ក្នុងគោលបំណងដោះស្រាយបញ្ហាខាងលើ និងដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងពង្រឹងការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម÷

១. មិនអនុញ្ញាតឱ្យស្នើសុំថវិកាបុរេប្រទាន ដែលគ្មានប្រភពឥណទានទូទាត់។

២. ត្រូវរៀបចំកម្មវិធីឥណទានសម្រាប់ទូទាត់ថវិកាបុរេប្រទាននានា ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់បុរេប្រទានកន្លងមក តាមឆ្នាំនីមួយៗឱ្យបានដាច់ខាត។

៣. ចំពោះគម្រោងនានា ដែលបានរៀបចំកម្មវិធីឥណទានទូទាត់ជាពហុឆ្នាំរួច ការបើកផ្ដល់បន្តទៀតសម្រាប់គម្រោងនីមួយៗដែលបានទទួលថវិកាបុរេប្រទានហើយនោះ គឺត្រូវរង់ចាំដល់ឆ្នាំដែលមានឥណទានសម្រាប់ទូទាត់ជាក់ស្ដែង។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្ដម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត** មេត្តាជ្រាប និងអនុវត្តតាមគោលការណ៍ណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

សូម **ឯកឧត្ដម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត** ទទួលនូវការគោរពរាប់អានពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-គ្រប់រដ្ឋបាលរាជធានី ខេត្ត

-គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

-គ្រប់រតនាគាររាជធានី ខេត្ត

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ